# របាយការណ៍

## សិក្ខាសាលាថ្នាក់តំបន់ ដើម្បីពិនិត្យឡើងវិញ
## អំពី
## វដ្តនៃការធ្វើផែនការ-ការអនុវត្ត-ការពិនិត្យមើល-ការកែតម្រូវសកម្មភាព
## ដើម្បីលើកកម្ពស់គុណភាពសេវាថែទាំ និងព្យាបាលជំងឺអេដស៍

Regional Review Workshop Following Plan-Do-Check-Act (P-D-C-A) Cycleto Improve ART Services

ថ្ងៃចន្ទ ៩រោច ដល់ថ្ងៃអង្គារ ១០រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥

ត្រូវនឹងថ្ងៃទី២៥ ដល់ ២៦ ខែមេសា ឆ្នាំ២០២២/ 25-26 April, 2022

ខេត្តតាកែវ/ Takeo Province




**រៀបចំដោយ**

**ឧបត្ថម្ភដោយ**

US CDC Cambodia

# របាយការណ៍

## សិក្ខាសាលាថ្នាក់តំបន់ ដើម្បីពិនិត្យឡើងវិញ
## អំពី
## វដ្តនៃការធ្វើផែនការ-ការអនុវត្ត-ការពិនិត្យមើល-ការកែតម្រូវសកម្មភាព ដើម្បីលើកកម្ពស់គុណភាពសេវាថែទាំ និងព្យាបាលជំងឺអេដស៍

Regional Review Workshop Following Plan-Do-Check-Act (P-D-C-A) Cycleto Improve ART Services

**១. ទីកន្លែងនៃវគ្គសិក្ខាសាលា៖** នៅសាលប្រជុំនៃមន្ទីរសុខាភិបាលខេត្តតាកែវ

**២. កាលបរិច្ឆេទនៃវគ្គសិក្ខាសាលា៖** ថ្ងៃចន្ទ ៩រោច ដល់ថ្ងៃអង្គារ ១០រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី ២៥ ដល់ ២៦ ខែមេសា ឆ្នាំ២០២២

**៣. គោលបំណង៖**

- ដើម្បីពិនិត្យឡើងវិញជាបន្តបន្ទាប់វិភាគមូលហេតុដើមនៃបញ្ហាបង្កើតផែនការកែលម្អ និងតាមដាន ដែលទាក់ទងទៅនឹងសូចនាករនៃគ្លីនិកដែលត្រូវអនុវត្តនៅក្នុងសេវាថែទាំនិងព្យាបាលជំងឺអេដស៍
- ពិនិត្យសូចនាករ រួមមាន៖
  - % អ្នកជំងឺ ART ដែលបានស្លាប់
  - % អ្នកជំងឺ ART ដែលខកថ្ងៃណាត់តិចជាងឬស្មើ២៨ថ្ងៃ បានត្រលប់ចូលមកវិញ ក្នុងសេវាART
  - % អ្នកជំងឺ ART ដែលបាត់មុខលើសពី២៨ថ្ងៃ បានត្រលប់ចូលមកវិញ ក្នុងសេវាART
  - % ការមកពិនិត្យតាមការណាត់ជួប
  - % អ្នកជំងឺផ្តើមARTថ្មី នៅក្នុងត្រីមាស ដែលចាប់ផ្តើមការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ក្នុងថ្ងៃតែមួយនឹងថ្ងៃធ្វើរោគវិនិច្ឆ័យថាមានផ្ទុកមេរោគអេដស៍
  - % អ្នកជំងឺដែលសមស្របធ្វើVL តេស្តនៅក្នុងត្រីមាស បានធ្វើVLតេស្ត
  - % លទ្ធផលVLតេស្តបានត្រឡប់មកដល់គ្លីនិកវិញក្នុងអំឡុងពេល១៤ថ្ងៃ
  - % អ្នកជំងឺកំពុងទទួលART មានVL suppressed
  - ចំនួន និង %អ្នកជំងឺដែលបានបញ្ចប់TPTមកទល់នឹង ខែមីនា ២០២២
  - ចំនួន និង % អ្នកជំងឺបានទទួលឱសថនិងការណាត់ជួប ≥ 3 months មកទល់នឹង ខែមីនា ២០២២
  - % អ្នកជំងឺផ្តើមARTថ្មីដោយឱសថTLD

- ○ % អ្នកជំងឺ ARTសរុប បានទទួល ឱសថ TLD មកទល់នឹង ខែមីនា ២០២២
- ដើម្បីពិភាក្សាពីផែនការសកម្មភាពដែលត្រូវអនុវត្តបន្ត (ផែនការកែលម្អសេវា)

## ៥. លទ្ធផល

នាថ្ងៃទី ២៥ ដល់ថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០២២ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បានរៀបចំសិក្ខាសាលាថ្នាក់តំបន់ ដើម្បីពិនិត្យ ឡើងវិញអំពី "វដ្តនៃការធ្វើផែនការ-ការអនុវត្ត-ការពិនិត្យមើល-ការកែតម្រូវសកម្មភាពដើម្បីលើកកម្ពស់គុណភាពសេវាថែទាំ និង ព្យាបាលជំងឺអេដស៍ " ក្រោមការឧបត្ថមថវិកា US-CDS Cambodia នៅសាលប្រជុំមន្ទីរសុខាភិបាលខេត្តតាកែវ។ សិក្ខាសាលានេះក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ លោកវេជ្ជ. **សំរិត សុវណ្ណារិទ្ធ** អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ លោកឱសថការី **ឆាន់ ទ៉ាន់** អនុប្រធានមន្ទីរសុខាភិបាលខេត្តតាកែវ និងលោកវេជ្ជ. **ចាន់ សុជាតា** តំណាង US CDC Cambodia។ សិក្ខាសាលានេះបានអញ្ជើញនឹងបានចូលរួមពីតំណាងស្ថាប័នម្ចាស់ជំនួយ អង្គការពាក់ព័ន្ធ នឹងមន្ត្រីនៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ មកពី Technical Bureau NCHADS Clinic PASP Manager and Staff of PASP និងមកពីខេត្តនានាសរុបចំនួន ៤៤ នាក់ ក្នុងនោះមានស្រីចំនួន ១៤ នាក់។ ហើយសិក្ខាកាមទាំងអស់ត្រូវបានអញ្ជើញមកពីខេត្ត/រាជធានីចំនួន៦ មាន: **ខេត្តកំពង់ស្ពឺ កោះកុង កំពត កែប ព្រះសីហនុ នឹងរាជធានី** ដោយខេត្តនិមួយៗ អញ្ជើញចូលរួមពី ប្រធានកម្មវិធីអេដស៍ខេត្ត ប្រធានក្រុមផ្នែកសេវា ART គ្រូពេទ្យផ្នែកសេវា ART មន្ត្រីទិន្នន័យនៃមន្ទីរសុខាភិបាល មន្ត្រីផ្នែក Data Clerk និងអ្នកផ្តល់ប្រឹក្សាសេវា ART ដល់អ្នកជំងឺអេដស៍តាមសេវានិមួយៗ។







**បន្ទាប់ពីកិច្ចស្វាគមន៍ មតិចំណាប់អារម្មណ៍ និងប្រកាសបើកវគ្គរបស់គណៈអធិបតីរួចមក ក្រុមការងារបាន៖**

- ធ្វើការណែនាំឲ្យស្គាល់គ្នា
- ការបង្ហាញពីគោលបំណង និងការរំពឹងទុករបស់វគ្គ
- ការបង្ហាញពីរបៀបវារៈ។

**ជាកិច្ចបន្ទាប់ការធ្វើបទបង្ហាញពី៖**

- ពិនិត្យលទ្ធផលនៃការអនុវត្តការងារថែទាំ-ព្យាបាលជំងឺអេដស៍ ត្រឹមត្រីមាសទី១ ឆ្នាំ ២០២២ នៅគ្រប់សេវាទូទាំងប្រទេស (សំនួរ & ចម្លើយ)៖
























## ៦. សន្និដ្ឋាន

សិក្ខាសាលាថ្នាក់តំបន់ ដើម្បីពិនិត្យឡើងវិញអំពី "វដ្តនៃការធ្វើផែនការ-ការអនុវត្ត-ការពិនិត្យមើល-ការកែតម្រូវសកម្មភាពដើម្បីលើកកម្ពស់គុណភាពសេវាថែទាំ និងព្យាបាលជំងឺអេដស៍" ក្រោមការឧបត្ថមថវិកា US-CDS Cambodia នៅសាលប្រជុំមន្ទីរសុខាភិបាលខេត្តតាកែវ រយៈពេលពីរថ្ងៃពេញ ក្រោមការឧបត្ថមថវិកា US-CDS Cambodia បានបញ្ចប់ប្រកបដោយជោគជ័យ។ សិក្ខាកាមដែលបានចូលរួមទាំងអស់ បានទទួលចំណេះដឹងបន្ថែមពីសូចនាករបន្ទុកមេរោគសំខាន់ៗចំនួនប្រាំមួយ។ ប្រធានក្រុម គ្រូពេទ្យ និងមន្ត្រីទិន្នន័យនៃសេវា ART ទាំងអស់បានប្តេជ្ញាចិត្តនឹងបង្កើនការធ្វើឲ្យប្រសើរឡើងវិញទាំងការអនុវត្ត ការពិនិត្យមើល និងការតម្រូវសកម្មភាពដើម្បីឲ្យសេវាថែទាំ និងព្យាបាលជំងឺអេដស៍ កាន់តែល្អប្រសើរឡើង។ មុននឹងបិទវគ្គសិក្ខាសាលានេះ លោកឱសថការី **ឆាន់ ទ៉ាន់** អនុប្រធានមន្ទីរសុខាភិបាលខេត្តតាកែវបានមានប្រសាសន៍ផ្តល់នូវមតិផ្តាំផ្ញើដល់សិក្ខាកាមដើម្បីឈានទៅសម្រេចទិសដៅថ្នាក់ជាតិ ៩៥% ៩៥% ៩៥% ក្នុងឆ្នាំ ២០២៥។